- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមការចាំបាច់

## សំរេច

**ប្រការ ១ :** ប្រគល់ការកិច្ចជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជារដ្ឋមន្ត្រីស្តីទីក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃ ឯកឧត្តម **ចែម ស្គួន** ត្រឡប់មកពីបំពេញបេសកកម្មនៅក្រុងបាងកកវិញ ។

**ប្រការ ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ស ខេង** ត្រូវទទួលអនុវត្តសេចក្តី សំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ៣៦ សសរ
## ស្តីពីការបង្កើតគណៈកម្មការចំរុះសំរាប់ពង្រីក
## សហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា
## ជាមួយសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិត ឡាវ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញសេចក្ដីប្រកាសរួមរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញកិច្ចព្រមព្រៀង ស្ដីពីការបង្កើតគណៈកម្មការចំរុះខាងសហប្រតិបត្តិការរវាងរដ្ឋាភិបាលទាំងពីរ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះ សំរាប់ពង្រីកសហប្រតិបត្តិការកម្ពុជា - ឡាវ ដែលមានសមាសភាពដូចខាងក្រោម :

១- ព្រះអង្គស្ដេចក្រុមឃុន នរោត្តម សិរី វុឌ្ឍ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិ ការអន្តរជាតិ ប្រធាន

២- តំណាងក្រសួងផែនការ ( ថ្នាក់នាយកដ្ឋាន ) សមាជិក

៣- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ( ថ្នាក់នាយកដ្ឋាន ) សមាជិក

៤- តំណាងក្រសួងពាណិជ្ជកម្ម ( ថ្នាក់នាយកដ្ឋាន ) សមាជិក

៥- តំណាងក្រសួងអប់រំយុវជន និង កីឡា ( ថ្នាក់នាយកដ្ឋាន ) សមាជិក

៦- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ( ថ្នាក់នាយកដ្ឋាន ) សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានតួនាទី និង ភារកិច្ចដូចតទៅ :

- សិក្សារៀបចំគំរោង និងវិធានការសហប្រតិបត្តិការរវាងប្រទេសទាំងពីរ
- ជំរុញការអនុវត្តន៍កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ
- ត្រួតពិនិត្យការអនុវត្តន៍កិច្ចសហប្រតិបត្តិការ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា
- សំរបសំរួលជាមួយបណ្ដាក្រសួង - ស្ថាប័នពាក់ពន្ធ័ទៅនឹងកិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ
- រាយការណ៍ជូនរាជរដ្ឋាភិបាលនូវបណ្ដាលទ្ធផលនៃការអនុវត្តន៍ ។

**ប្រការ ៣ :** គណៈកម្មការចំរុះនេះ មានសិទ្ធិអញ្ជើញឯកឧត្ដមអស់លោករដ្ឋមន្ត្រី ឬ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីចូល រួមបំពេញការងារ ស្របតាមការងារសហប្រតិបត្តិការប្រទេសទាំងពីរ ។

**ប្រការ ៤ :** សមាជិកទាំងអស់ របស់គណៈកម្មការនេះ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញ និង ណែនាំរបស់ ប្រធានគណៈកម្មការ ។

**ប្រការ ៥** : គណៈកម្មការចំរុះនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរ-ជាតិដើម្បីបំពេញការងាររបស់ខ្លួន ។

**ប្រការ ៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន ដែលមានការពាក់ពន្ធ័ និង សាមីជន ដែលមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខា និង ត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

***

*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៤*

# សេចក្តីសំរេចលេខ ៣៧ សសរ
# ស្តីអំពីការផ្ទេរភារកិច្ច

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ខណ្ណ ម៉ូលីខណ្ណ**

## សំរេច

**ប្រការ ១** : ត្រូវបានប្រគល់សិទ្ធិបន្ថែមជូនឯកឧត្តម **តាក ឈន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារនិតិសម្បទា និងអភិវឌ្ឍន៍ជា ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំដែនដី និង នគរូបនីយកម្ម ស្តីទីនៅពេលដែលឯកឧត្តម **ខណ្ណ ម៉ូលីខណ្ណ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈរៀបចំដែនដី និងនគរូបនីយកម្ម អញ្ជើញទៅសំរាកព្យាបាល រោគនៅបរទេស ចាប់ពីថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៤ រហូតដល់ឯកឧត្តមវិលត្រឡប់មកវិញ ។